**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

**ភាគីដាក់ឯកសារ:** ក្រុមមេធាវីការពារក្តីលោក មាស មុត

**ដាក់ជូន:** សហចៅក្រមស៊ើបអង្កេត

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Jan-2014, 14:22
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ:** សម្ងាត់បំផុត/Strictly Confidential

**ចំណាត់ថ្នាក់ប្រភេទឯកសារ:** **ប្តូរទៅជាសាធារណៈ**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:**

**ឈ្មោះមន្រ្តីកត់ត្រា:**

**ហត្ថលេខា:**

---

***សំណើរបស់ មាស មុត សុំការអនុញ្ញាតដើម្បីឆ្លើយតបទៅនឹង ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណើជាបន្ទាន់របស់ មាស មុត សុំឲ្យ ក.ស.ច.ស ពិចារណាឡើងវិញ ថាតើ ក.ស.ច.ស មានយុត្តាធិការសម្រេចអំពីទំនាស់ផលប្រយោជន៍ដែរឬអត់***

---

ដាក់ដោយ៖

**សហមេធាវីការពារក្តី៖**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

ផ្ញើជូន៖

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Mark B. HARMON

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

អនុលោមតាមមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារទៅចំពោះមុខ អ.វ.ត.ក និង តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") លោក មាស មុត ស្នើសុំការអនុញ្ញាតដើម្បីធ្វើការឆ្លើយតបទៅនឹង*ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធទៅនឹងសំណើជាបន្ទាន់របស់លោក មាស មុត សុំឲ្យ ក.ស.ច.ស ពិចារណាឡើងវិញ ថាតើ ក.ស.ច.ស មានយុត្តាធិការសម្រេចអំពីទំនាស់ផលប្រយោជន៍ដែរឬអត់នោះ*[1]។ ទោះបីជាត្រូវបានដាក់ចំណងជើងថា "ការឆ្លើយតប" ក្តី ក៏តាមពិតទៅសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺជាចម្លើយតបទៅនឹងសំណើជាបន្ទាន់[2] ដាក់ដោយក្រុមមេធាវីការពារក្តីដែលជាភាគីដើមបណ្តឹង។ ជាការពិតហើយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានអញ្ជើញឲ្យ ក.ស.ព "ដាក់ចម្លើយតប" ទៅនឹងសំណើជាបន្ទាន់ មិនមែនឲ្យធ្វើការឆ្លើយតបទៅនឹងសំណើជាបន្ទាន់នោះទេ[3]។ អនុលោមតាមសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៨.៥៖ "ការឆ្លើយតបទៅនឹងចម្លើយតប ត្រូវបានអនុញ្ញាតតែក្នុងករណីដែលមិនមានការស្នើសុំឲ្យមានការសួរដេញដោលផ្ទាល់មាត់តែប៉ុណ្ណោះ ..."។ ការសួរដេញដោលផ្ទាល់មាត់មិនត្រូវបានស្នើសុំ ឬ មិនត្រូវបានកំណត់កាលបរិច្ឆេទទាក់ទងទៅនឹងយុត្តាធិការរបស់ ក.ស.ច.ស ទៅលើទំនាស់ផលប្រយោជន៍នោះឡើយ។ កាលពីមុន សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុញ្ញាតឲ្យ ក.ស.ព ធ្វើការឆ្លើយតបទៅនឹងចម្លើយតបនានារបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងបញ្ហាទំនាស់ផលប្រយោជន៍ ដែលបានចោទប្រកាន់នេះ[4]។ ក្រុមមេធាវីការពារក្តីស្នើសុំឲ្យមានការអនុញ្ញាតប្រហាក់ប្រហែលគ្នានេះ ដើម្បីធ្វើការឆ្លើយតបទៅនឹង

---

[1] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណើជាបន្ទាន់របស់ មាស មុត សុំឲ្យ ក.ស.ច.ស ពិចារណាឡើងវិញ ថាតើខ្លួនមានយុត្តាធិការដើម្បីធ្វើការកំណត់អំពីទំនាស់ផលប្រយោជន៍ដែលបានចោទប្រកាន់នេះដែរ ឬយ៉ាងណា ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារលេខ D56/16/1។

[2] សំណើជាបន្ទាន់របស់ មាស មុត សុំឲ្យ ក.ស.ច.ស ពិចារណាឡើងវិញ ថាតើខ្លួនមានយុត្តាធិការដើម្បីសម្រេចអំពីទំនាស់ផលប្រយោជន៍ដែលបានចោទប្រកាន់នេះដែរ ឬយ៉ាងណា ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារលេខ D56/17 ("សំណើជាបន្ទាន់")។

[3] ដីកាសម្រេចលើសំណើជាបន្ទាន់របស់ មាស មុត ស្តីពីយុត្តាធិការរបស់ ក.ស.ច.ស ក្នុងការសម្រេចលើទំនាស់ផលប្រយោជន៍ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារលេខ D56/16 កថាខណ្ឌ ៥។

[4] *សូមមើល* សេចក្តីសម្រេច និង ការកំណត់កាលបរិច្ឆេទទាក់ទងនឹងសំណើសុំការតែងតាំងសហមេធាវីដែលបានជ្រើសតាំង ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារលេខ D56/3 កថាខណ្ឌ ៣០។ សេចក្តីសម្រេច និង ការកំណត់កាលបរិច្ឆេទឡើងវិញលើកទីពីរ ទាក់ទងនឹងសំណើសុំការតែងតាំងសហមេធាវីដែលបានជ្រើសតាំង ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារលេខ D56/5 កថាខណ្ឌ ១៥។

ករណីនេះ។ ការឆ្លើយតប គឺជាការចាំបាច់ដើម្បីដោះស្រាយទៅលើចំណុចទាំងឡាយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ៖

- ការបកស្រាយវិធាន ១១(៦) នៃវិធានផ្ទៃក្នុង។
- ការបកស្រាយទៅលើ*ដីកាសម្រេចលើសំណើសុំ និង សារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវីការពារ* ដែលបានដាក់ទៅក្នុងសំណុំរឿង ០០៤[5]។
- ជំហរក្នុងការលើកឡើងអំពីទំនាស់ផលប្រយោជន៍ជូន ក.ស.ច.ស និង ការបកស្រាយរបស់ខ្លួនទៅលើយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ដែលពាក់ព័ន្ធនឹងបញ្ហានេះ។
- ការបកស្រាយទៅលើយុត្តាធិការរបស់ ក.ស.ច.ស ដើម្បីបើកសវនាការទៅលើសំណើ "តែម្ខាង" ទាក់ទងនឹងទំនាស់ផលប្រយោជន៍ និង
- ការបកស្រាយទៅលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលនាពេលថ្មីៗនេះ និងភាពពាក់ព័ន្ធនៃយុត្តិសាស្ត្រនេះ ទៅនឹងយុត្តាធិការរបស់អង្គភាពគាំពារការការពារក្តី និង គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទៅលើបញ្ហាទំនាស់ផលប្រយោជន៍នានា។

មេធាវីការពារក្តីស្នើសុំដាក់ការឆ្លើយតបនេះជាភាសាអង់គ្លេសជាមុនសិន ហើយនឹងដាក់អត្ថបទបកប្រែជាភាសាខ្មែរនៅពេលក្រោយ ដោយសារមានមូលហេតុថា អង្គភាពបកប្រែភាសាមិនអាចធ្វើការបកប្រែឲ្យទាន់ពេលវេលាបាន[6]។

**ហេតុដូច្នេះ** យោងទៅលើមូលហេតុទាំងឡាយ ដូចបានបញ្ជាក់ជូនខាងលើ មេធាវីការពារក្តីស្នើសុំការអនុញ្ញាតដោយក្តីគោរព ដើម្បីធ្វើការឆ្លើយតបទៅនឹង*ចម្លើយតបរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងសំណើជាបន្ទាន់របស់លោក មាស មុត សុំឲ្យ ក.ស.ច.ស ពិចារណាឡើងវិញ ថាតើ ក.ស.ច.ស មានយុត្តាធិការសម្រេចអំពីបញ្ហាទំនាស់ផលប្រយោជន៍ដែរឬយ៉ាងណានោះ*។

យើងខ្ញុំសូមដាក់សំណើសុំនេះជូនសហចៅក្រមស៊ើបអង្កេតដោយក្តីគោរព។

---

[5] ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស៖ ដីកាសម្រេចលើសំណើសុំ និង សារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារលេខ D122/6។

[6] *សូមមើល* អ៊ីមែលផ្ញើមកពីអង្គភាពបកប្រែភាសា ជូនក្រុមមេធាវីការពារក្តី "កម្មវត្ថុ៖ សំណើសុំឲ្យធ្វើការបកប្រែ" ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៣។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៨** ខែ **ធ្នូ** ឆ្នាំ **២០១៣**

សហមេធាវីការពារក្ដីលោក មាស មុត

_________________ _____________________

អាង ឧត្តម Michael G. KARNAVAS